សកម្មភាព ៖ **ល្បែងឡូតូសត្វពាហនៈ**

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយសង្កេត)

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**ភាសាខ្មែរ**

ប្រើពាក្យសំដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (និមិត្តសញ្ញាតំណាងឱ្យសត្វ និងវត្ថុនានា)។

ការស្គាល់តួរអក្សរ (ការប្រើញាណរបស់ខ្លួនដើម្បីអភិវឌ្ឍបំណិនសមត្ថភាពទាំង៦)។

(ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំម្លេង)។

**គោលបំណង** ៖

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាបឬលើសពីនេះ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**(ភាសាខ្មែរ)** ប្រាប់ពីឈ្មោះសត្វ តាមរយៈការធ្វើចលនាកាយវិការគ្រាប់តាមនិមិត្តសញ្ញា។

ប្រាប់ឈ្មោះសត្វ វត្ថុផ្សេងៗដោយស្តាប់សំឡេង ឬ សង្កេតកាយវិការ។

ស្តាប់ និងបែងចែកសូរសម្លេងដូចជាសូរសម្លេងសត្វ សម្លេងមនុស្ស និងដឹងពីប្រភពសម្លេង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង ៉កុមារគំរូ ៉

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ រៀបចំកាតុងឡូតូរូបសត្វពាហនៈ។ (1-B, 1-C, 2-B, 2-C, 3-B, 3-C, 4-B, 4-C, 5-B, 5-C, 6-B, 6-C, 7)

កាតរូបសត្វពាហនៈចំនួន ៦ប្រភេទកាត់រួចដាក់ក្នុង កាបូប ឬ ធុងជ័រ។

គម្របដប ឬ ដុំតូចៗសម្រាប់សម្គាល់ចំនួននៅលើកាតុងឡូតូរូបសត្វពាហនៈ។

**ការរៀបចំ** ៖ រៀបចំអង្គុយជាក្រុម ចែកឧបករណ៍ ជ្រើសក្មេងម្នាក់ធ្វើជាមេ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងឡូតូរូបសត្វពាហនៈ**ជាមួយកូនៗទាំងអស់គ្នា
2. តើនៅក្នុងប្រទេសកម្ពុជាមានសត្វអ្វីខ្លះ?
   បាទ/ចាស សត្វ គោ តោ ក្របី ខ្លា មាន់ ទា…….។
3. តោះកូនៗមើលកាតុងឡូតូទាំងអស់គ្នា។
   តើក្នុងកាតុងឡូតូនេះជាសត្វអ្វី? សត្វ គោ តោ ក្របី ខ្លា មាន់ ទា…….។
4. សត្វទាំងអស់នេះមានប្រយោជន៍ណាស់សម្រាប់ប្រទេសកម្ពុជាយើង ។
5. សរសេរពាក្យ **ស្មើតែផុតពូជ** នៅលើក្តារខៀន និងពន្យល់ប្រាប់ក្មេងៗ។
6. ពន្យល់ពីរបៀបលេង**ល្បែងឡូតូសត្វពាហនៈ**ដល់ក្មេងៗ
   - ចែកក្មេងៗជាក្រុមតាមចំនួនជាក់ស្តែង។
   - ត្រូវចែកកាតុងឡូតូល្បែងសត្វពាហនៈតាមក្រុមនីមួយៗមួយឈុត និងដុំតូចៗ ឬកំរបដបក៏បានចំនួន ៦ដុំដូចគ្នា។
   - ជ្រើសរើសក្មេងម្នាក់ជាអ្នកក្រឡុករូបសត្វពាហនៈ ចាប់យកកាតមួយសន្លឹកបន្ទាប់មកហៅឈ្មោះសត្វនោះឱ្យលឺ។
   - បើក្មេងៗណាមានសត្វដូចដែលគេហៅឈ្មោះនោះនៅក្នុងកាតុងឡូតូល្បែងរូបសត្វពាហនៈ ក្មេងនោះត្រូវដាក់ដុំតូចៗ ឬកំរបដបសម្គាល់នោះនៅលើវា ។
   - បន្ទាប់មកក្មេងចាប់ផ្តើមហៅឈ្មោះម្តងទៀត និងធ្វើដូចខាងលើដដែលរហូត។
   - ក្មេងណាដែលបានបំពេញលើកាតុងល្បែងឡូតូរូបសត្វបាហនៈនោះពេញមុននឹងក្លាយជាអ្នកឈ្នះតែម្តង។
   - បន្ទាប់មកអ្នកអាចលេងបន្តរកឈ្នះ ២ ឬ ៣ នាក់បន្តទៀតក៏បាន ។